អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៤-០៨-២០០៦
**លេខស៊ើបសួរ:** ០០១/១៨-០៧-២០០៧
**បណ្តឹងឧទ្ធរណ៍លេខ:** ០០១/២៨-០៨-២០០៧

# អង្គបុរេជំនុំជម្រះ

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន
ចៅក្រម ហួត វុទ្ធី
ចៅក្រម Rowan Downing
ចៅក្រម នេយ ថុល
ចៅក្រម Katinka Lahuis

**កាលបរិច្ឆេទ:** ០៩ តុលា ២០០៧

---

**សាធារណៈ**

## សេចក្តីសម្រេចអំពីសវនាការជាសាធារណៈ

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH

**ជនត្រូវចោទ**
កាំង ហ្គេកអ៊ាវ

**មេធាវីការពារ**
ការ សាវុត្ថ
François ROUX

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានឃើញ** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ចុះថ្ងៃទី ៣១ កក្កដា ២០០៧។

**បានឃើញ** សេចក្តីសង្ខេបបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៣១ កក្កដា ២០០៧ របស់សហចៅក្រមស៊ើបអង្កេត ធ្វើដោយមេធាវីតំណាងអោយជនត្រូវចោទ នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧ ។

**បានឃើញ** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ធ្វើនៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ ។

**ពិចារណានៅលើ** ការស្នើសុំរបស់មេធាវីការពារជនត្រូវចោទ និងការស្នើសុំរបស់សហព្រះរាជអាជ្ញា សំណូមពរសុំអោយសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ ធ្វើឡើងជាសាធារណៈ ។

**ដោយអនុលោម** តាមវិធាន ៧៧(៦) នៃវិធានផ្ទៃក្នុង ដែលអនុម័តកាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ។

**សម្រេចជាឯកច្ឆន្ទ**

បើកសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ដែលធ្វើដោយមេធាវីជនត្រូវចោទ កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧ **ជាសាធារណៈ** នៅថ្ងៃ ខែ ឆ្នាំ ដែលត្រូវកំណត់នៅពេលក្រោយ។

ភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៧

**ជ. អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន**